00750475

E133

**សាធារណៈ / Public**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ០២ ខែ វិច្ឆិកា ឆ្នាំ ២០១១

**ជូនចំពោះ:** - ភាគីទាំងអស់នៃសំណុំរឿង ០០២
- ការិយាល័យរដ្ឋបាល
- ផ្នែកគ្រប់គ្រងតុលាការ

**ពី :** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** ចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** ការឈប់សម្រាករបស់អង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ

អង្គជំនុំជម្រះសាលាដំបូងសូមជម្រាបជូនដល់ភាគីដែលពាក់ព័ន្ធទាំងអស់ឲ្យបានជ្រាបថា អង្គជំនុំជម្រះសាលាដំបូងនឹងឈប់សម្រាកក្នុងឱកាសបុណ្យអុំទូក អកអំបុក និងសំពះព្រះខែ ចាប់ពីថ្ងៃចន្ទ ទី ០៧ រហូតដល់ ថ្ងៃសុក្រ ទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១១។ ក្នុងអំឡុងពេលនៃការឈប់សម្រាកនេះ ផ្នែកគ្រប់គ្រងតុលាការ នឹងមិនទទួលសំណើដាក់ឯកសារណាមួយនៃសំណុំរឿង ០០២ ឡើយ។

ទោះបីយ៉ាងណាក៏ដោយ ពេលវេលាកំណត់ក្នុងការដាក់ឯកសារនៅតែត្រូវបានរាប់អំឡុងពេលឈប់សម្រាកនេះ។ ក្នុងករណីដែលពេលវេលាកំណត់ផុតនៅចំថ្ងៃណាមួយក្នុងអំឡុងពេលឈប់សម្រាកនេះ កាលបរិច្ឆេទផុតកំណត់នៃការទទួលសំណើដាក់ឯកសារនឹងលើកទៅថ្ងៃ ច័ន្ទ ទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02 / 11 / 2011
ម៉ោង (Time/Heure) : 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak